## ★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ លេខ 37 ★

បាទ/ចាស គាំទ្រសំណើប្រជាមតិ លេខ 37 - ពីព្រោះអ្នកគួរមានសិទ្ធិដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក។

*ការបោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិ 37 មានន័យ 3 យ៉ាង ៖*

- អ្នកនឹងមានសិទ្ធិដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក និង ថាតើចំណីអាហាររបស់អ្នកត្រូវបានផលិតដោយប្រើវិស្វកម្មពន្ធុយ៉ាងណា។
- ចំណីអាហារនឹងត្រូវបិទស្លាកយ៉ាងត្រឹមត្រូវ។ ស្លាកទាំងឡាយនៅលើចំណីអាហារ ត្រូវតែបង្ហាញឲ្យដឹងប្រសិនបើផលិតផលនោះត្រូវបានផលិតតាមរយៈវិស្វកម្មពន្ធុ។
- ការការពារសុខភាពគ្រួសាររបស់អ្នកនឹងកាន់តែមានភាពងាយស្រួលជាងមុន។ អ្នកនឹងទទួលបានព័ត៌មានដែលអ្នកត្រូវការអំពីចំណីអាហារដែលពេទ្យ និងអ្នកវិទ្យាសាស្ត្រអះអាងថា មានទំនាក់ទំនងទៅនឹងប្រតិកម្ម និងគ្រោះថ្នាក់ធំៗដទៃទៀតចំពោះសុខភាព។

ចំណីអាហារដែលយើងទិញមានព័ត៌មានអំពីសារធាតុចិញ្ចឹមរួចទៅហើយនៅលើស្លាករបស់វា។ ជាមួយនឹងសំណើប្រជាមតិ 37 យើងនឹងមានព័ត៌មានដែលសរសេរជាភាសាសាមញ្ញ ប្រសិនបើចំណីអាហារនោះត្រូវបានផលិតឡើងដោយវិស្វកម្មពន្ធុ ដែលមានន័យថាចំណីអាហារនោះមាន DNA (អាស៊ីដឌីអុកស៊ីរីបូនុយក្លេអ៊ិច) ដែលត្រូវបានធ្វើការកែប្រែបែបសិប្បនិម្មិតនៅក្នុងមន្ទីរពិសោធន៍ដោយប្រើប្រាស់ពន្ធុពីវីរុស បាក់តេរី ឬ រុក្ខជាតិ ឬសត្វផ្សេងៗទៀត។

ដោយសារតែចំណីអាហារកែច្នៃពន្ធុមានភាពចម្រូងចម្រាស មានប្រទេស*ជាង 40 ជុំវិញពិភពលោកត្រូវការឲ្យមានស្លាកសម្រាប់ចំណីអាហារវិស្វកម្មពន្ធុ* ក្នុងនោះមានប្រទេសភាគច្រើនបំផុតនៅក្នុងទ្វីបអឺរ៉ុប ប្រទេសជប៉ុន និងសូម្បីតែប្រទេសចិន និងឥណ្ឌា។ តើក្រុមហ៊ុនអាមេរិកទាំងឡាយមិនគួរផ្តល់ឲ្យពលរដ្ឋអាមេរិកនូវព័ត៌មានដូចគ្នាទៅនឹងអ្វីដែលពួកគេផ្តល់ទៅឲ្យជនបរទេសមែនឬទេ?

មិនមានការសិក្សារយៈពេលវែងអំពីសុខភាពដែលបានបង្ហាញថា ចំណីអាហារវិស្វកម្មពន្ធុមានសុវត្ថិភាពចំពោះមនុស្សនោះទេ។ មិនថាអ្នកទិញចំណីអាហារវិស្វកម្មពន្ធុ ឬអត់នោះទេ អ្នកមានសិទ្ធិដឹងអំពីអ្វីដែលអ្នកកំពុងតែទិញ និងមិនត្រូវប្រថុយប្រថានចំពោះសុខភាពគ្រួសាររបស់អ្នកឡើយ។ ការបិទស្លាកជួយឲ្យអ្នកដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់យើង ដូច្នេះយើងអាចធ្វើការពិចារណាសម្រាប់ខ្លួនយើងផ្ទាល់។

សំណើប្រជាមតិ 37 គឺជាវិធានការសាមញ្ញប្រកបដោយសុភវិនិច្ឆ័យមួយ។ វាមិនចំណាយប្រាក់អ្វីឡើយសម្រាប់ការដាក់បញ្ចូលព័ត៌មានទៅក្នុងស្លាកមួយ ហើយវាត្រូវបានអនុវត្តដោយផ្តល់ពេលវេលាឲ្យផលិតករធ្វើការព្រីនចេញនូវស្លាកថ្មីៗដែលប្រាប់អ្នកពីអ្វីដែលនៅក្នុងចំណីអាហារនោះ ឬ ធ្វើការផ្លាស់ប្តូរផលិតផលរបស់ពួកគេប្រសិនបើពួកគេមិនចង់លក់ចំណីអាហារដែលកែច្នៃពន្ធុនោះ។

លើសពីនេះទៅទៀត សំណើប្រជាមតិ 37 ទប់ស្កាត់ការប្រើប្រាស់ខុសនូវពាក្យ "ធម្មជាតិ" ទៅលើផលិតផលកែច្នៃពន្ធុ។

ក្រុមហ៊ុនផលិតចំណីអាហារ និងក្រុមហ៊ុនកសិគីមីធំៗ និងអ្នកផ្សព្វផ្សាយបញ្ចុះបញ្ចូលរបស់ពួកគេប្រឆាំងនឹងវិធានការនេះ។ ក្រុមហ៊ុនជាច្រើនក្នុងចំណោមនេះ គឺជាក្រុមហ៊ុនដូចគ្នាទៅនឹងក្រុមហ៊ុនដែលបានកុហកពួកយើងអំពីផលប៉ះពាល់របស់ថ្នាំសម្លាប់សត្វល្អិត ឬ បានតស៊ូមិនបង្ហាញព័ត៌មានផ្សេងទៀតនៅលើស្លាកចំណីអាហារ ដូចជាចំនួនកាឡូរី ឬ បរិមាណជាតិខ្លាញ់ ឬ អ៊ីប៊ិលដែលមាននៅក្នុងផលិតផលរបស់ពួកគេ។ បច្ចុប្បន្ននេះ ពួកគេចង់ឃាំងយើងឲ្យនៅទីងងឹតមិនឲ្យដឹងពីវិស្វកម្មពន្ធុរបស់ពួកគេនៅក្នុងចំណីអាហាររបស់យើងឡើយ។

មិនថាអ្នកចង់ទទួលទានចំណីកែច្នៃពន្ធុ ឬអត់នោះទេ សំណើប្រជាមតិ 37 ផ្តល់ឲ្យអ្នកនូវអំណាចក្នុងការជ្រើសរើសចំណីអាហារអ្វីខ្លះសម្រាប់ទទួលទានក្នុងគ្រួសាររបស់អ្នក។ ក្រុមហ៊ុនគីមីធំៗមិនគួរធ្វើការសម្រេចចិត្តសម្រាប់អ្នកនោះទេ។

អ្នកប្រើប្រាស់ គ្រួសារកសិករ វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងគិលានុបដ្ឋាយិកា អ្នកឯកទេសអាហារូបត្ថម្ភ និងពាណិជ្ជករខ្នាតតូច និងពលរដ្ឋកាលីហ្វ័រញ៉ាជិតមួយលាននាក់បានចេញមុខចុះហត្ថលេខារួចរាល់ហើយទៅលើញត្តិដែលផ្តល់ឲ្យអ្នកនូវសិទ្ធិដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់យើង? តើអ្នកនឹងចូលរួមជាមួយពួកគេដែរ ឬទេ?

ចង់ដឹងព័ត៌មានបន្ថែម ឬ ចូលរួមជាមួយពួកគេឥឡូវនេះ សូមចូលទៅកាន់គេហទំព័រ *www.CARightToKnow.org.*

នៅពេលអ្នកបោះឆ្នោតសម្រេចលើសំណើប្រជាមតិ 37 សូមសួរខ្លួនឯងតែមួយសំណួរប៉ុណ្ណោះ ៖ តើខ្ញុំមានសិទ្ធិដឹងពីអ្វីដែលនៅក្នុងចំណីអាហារដែលខ្ញុំទទួលទាន និងចិញ្ចឹមគ្រួសារខ្ញុំបានដែរឬទេ? ចម្លើយ គឺបោះឆ្នោត *បាទ/ចាស លើសំណើប្រជាមតិ លេខ 37* ។

*www.CARightToKnow.org.*

**DR. MICHELLE PERRO**, វេជ្ជបណ្ឌិតផ្នែកកុមារ
**REBECCA SPECTOR**, នាយក West Coast មជ្ឈមណ្ឌល សំរាប់សុវត្ថិភាពចំណីអាហារ
**GRANT LUNDBERG**, មន្ត្រីនាយកប្រតិបត្តិ កសិកម្ម គ្រួសារ Lundberg



## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 37 ★

សំណើប្រជាមតិ 37 និយត្តកម្មអំពី "សិទ្ធិដើម្បីដឹង" គឺពិតជាផែនការឆបោកមួយពោរពេញដោយការលើកលែងចំពោះ អ្នកទទួលបានផលប្រយោជន៍ពិសេស និងតំលៃលាក់បាំងសំរាប់ អ្នកប្រើបាស្រ់និងអ្នកបង់ពន្ធ។

សំណើប្រជាមតិ 37 លើកលែងៈ ទឹកដោះគោ ឈីស្ស និង សាច់ពីតម្រូវការឲ្យបិទស្លាកឈ្មោះ។ វាលើកលែងស្រាបៀរ ស្រាទំពាំងបាយជូរ ស្រា អាហារដែលបានលក់នៅតាមភោជនីយដ្ឋាន និងអាហារផ្សេងទៀតដែលមានសារធាតុកែប្រែពន្ធុ។

តាមពិត វាលើកលែងពីរភាគបីនៃម្ហូបអាហារដែលពលរដ្ឋរដ្ឋ កាលីហ្វ័រញ៉ាប្រើប្រាស់ - រួមមានផលិតផលដែលផលិតដោយក្រុមហ៊ុន ដែលផ្តល់ថវិកាដល់យុទ្ធនាការសំណើប្រជាមតិ 37។

បង្កើតឲ្យមានបណ្តឹងទារយកប្រាក់ថ្មី

សំណើប្រជាមតិ 37 ត្រូវបានសរសេរដោយមេធាវីជំនុំជម្រះដែលជំនាញ ខាងការដាក់ពាក្យបណ្តឹងប្រឆាំងនឹងអាជីវកម្មនានា។ វាបង្កើតប្រភេទ ថ្មីមួយ នៃបណ្តឹងទារយកប្រាក់ដែលអនុញ្ញាតឲ្យមេធាវីទាំងឡាយអាច ប្តឹងអ្នកចំការ អ្នកលក់ឥវ៉ាន់ និងក្រុមហ៊ុនម្ហូបអាហារ - ដោយគ្មាន ភស្តុតាងនៃការរំលោភបំពាន ឬការបំផ្លាញឡើយ។

អ្នកប្រើប្រាស់នឹងទទួលបាននូវព័ត៌មានដែលធ្វើឲ្យយល់ខុស។

មានការសិក្សាជាលក្ខណៈវិទ្យាសាស្ត្រជាង 400 បានបង្ហាញពីចំណីអាហារដែលបានធ្វើដោយវិស្វកម្មពន្ធុ គឺមានសុវត្ថិភាព។ អង្គការសុខភាពនាំមុខគេនានាដូចជា សមាគមវេជ្ជសាស្ត្រអាមេរិក អង្គការ សុខភាពពិភពលោក បណ្ឌិតសភាជាតិផ្នែកវិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រ ដែលបានឈ្នះរង្វាន់ណូបែល 24 នាក់ និងរដ្ឋបាលគ្រប់គ្រងខាងចំណីអាហារ និងឱសថសហរដ្ឋអាមេរិក ក៏យល់ស្រប។

*"មិនមានយុត្តិកម្មផ្នែកវិទ្យាសាស្ត្រសម្រាប់ការបិទស្លាកពិសេសនៅលើចំណីអាហារផលិតតាមការកែច្នៃជីវសាស្ត្រឡើយ"* - សមាគមវេជ្ជសាស្ត្រអាមេរិក

តំលៃកាន់តែខ្ពស់សំរាប់អ្នកប្រើបាស្រ់និងអ្នកជាប់ពន្ធ

ការសិក្សាបង្ហាញថា ដោយការបង្ខំឲ្យផលិតផលចំណីអាហារទូទៅ ជាច្រើនមានការវេចខ្ចប់ឬធ្វើឡើងវិញជាមួយគ្រឿងផ្សំតំលៃកាន់តែថ្លៃ សំណើប្រជាមតិ 37 នឹងធ្វើឲ្យគ្រួសាររដ្ឋកាលីហ្វ័រញ៉ាកំរិតមធ្យម ចំណាយលុយរាប់រយដុល្លារបន្ថែមក្នុងមួយឆ្នាំសំរាប់គ្រឿងទេស។

ការវិភាគផលប៉ះពាល់សារពើពន្ធរបស់រដ្ឋជាផ្លូវការ សន្និដ្ឋានថាការចាត់ ចែងការិយាល័យធិបតេយ្យ និងពាក្យបណ្តឹងនឹងធ្វើឲ្យមានការចំណាយ ដល់អ្នកបង់ពន្ធរាប់លានដុល្លារ។

សូម្បីអ្នកផ្តល់ថវិកាដ៏ធំបំផុតរបស់សំណើប្រជាមតិ 37 សារភាពថា វា *"នឹងជាសុបិនអាក្រក់មួយខាងការរៀបចំទីកន្លែងដែលមានតំលៃថ្លៃ។"*

សំណើប្រជាមតិ 37 គឺជាល្បិចកលបោកនិងមានតំលៃថ្លៃមួយ។

បោះឆ្នោត ទេ!

*www.NoProp37.com*

**JONNALEE HENDERSON**
សហព័ន្ធការិយាល័យកសិដ្ឋាននៃរដ្ឋកាលីហ្វ័រញ៉ា
**DR. HENRY I. MILLER**, នាយកស្ថាបនិក
ការិយាល័យជីវបច្ចេកវិទ្យានៃរដ្ឋបាលគ្រប់គ្រងចំណីអាហារនិងឱសថ
**TOM HUDSON**, នាយកប្រតិបត្តិ
គណៈកម្មការការពារអ្នកបង់ពន្ធរដ្ឋកាលីហ្វ័រញ៉ា


*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# សំណើប្រជាមតិ អាហារដែលបានបំភ្លែពូជ។ ការដាក់ស្លាក។ លក្ខន្តិកៈផ្តួចផ្តើម។

# 37

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 37 ★

សំណើប្រជាមតិ 37 គឺមិនមែនជាវិធានការសាមញ្ញដូចដែលអ្នកផ្សព្វផ្សាយអះអាងនោះទេ។ វាជាការឆបោកមួយ មានគុណវិបត្តិនៃការបិទស្លាកលើចំណីអាហារដែលធ្វើឲ្យយល់ខុស និងខូចគុណភាពធ្ងន់ធ្ងរ ដែលនឹងបន្ថែមការចំណាយកាន់តែច្រើនទៅលើការិយាធិបតេយ្យរដ្ឋាភិបាល និងអ្នកបង់ពន្ធ បង្កើតជាបណ្តឹងគ្មានប្រយោជន៍ថ្មីៗទៀត និងបង្កើនការចំណាយលើចំណីអាហាររាប់ពាន់លានដុល្លារ- ដោយគ្មានផ្តល់ផលប្រយោជន៍ខាងសុខភាព និងសុវត្ថិភាពសោះ។ មិនតែប៉ុណ្ណោះ វាពោរពេញទៅដោយការលើកលែងសំរាប់ផលប្រយោជន៍ពិសេស។

សំណើប្រជាមតិលេខ 37 ប្រឆាំងជាមួយនឹងវិទ្យាសាស្ត្រ។

បច្ចេកវិទ្យាជីវសាស្ត្រ ដែលត្រូវបានហៅផងដែរថា ការកែច្នៃពន្ធ (GE) ត្រូវបានគេប្រើប្រាស់ជិតពីរទសវត្សរ៍មកហើយសម្រាប់ដាំដំណាំប្រភេទផ្សេងៗ ដូចជា ពោត សណ្តែកសៀង និងដំណាំដទៃទៀតដែលធន់នឹងជំងឺ និងសត្វល្អិត និងត្រូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតកាន់តែតិច។ ចំណីអាហារទូទៅរាប់ពាន់មុខត្រូវបានផលិតជាមួយនឹងគ្រឿងផ្សំដែលបានមកពីដំណាំដាំដោយបច្ចេកវិទ្យាជីវសាស្ត្រ។

សំណើប្រជាមតិ 37 ហាមឃាត់ចំណីអាហារដែលមានសុវត្ថិភាពបំផុតទាំងនេះនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ប្រសិនបើវាមិនត្រូវបានបិទស្លាកយ៉ាងពិសេស ឬ ផលិតឡើងវិញដោយប្រើប្រាស់គ្រឿងផ្សំដែលមានតម្លៃខ្ពស់ជាងមុនទេ។

រដ្ឋបាលគ្រប់គ្រងខាងចំណីអាហារនិងឱសថសហរដ្ឋអាមេរិកចែងថា គោលនយោបាយបិទស្លាកបែបនេះនឹងនាំឲ្យមាន *"ការកុហកដែលមិនអាចចៀសផុត"*។

អង្គការខាងវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រដែលទទួលបានការគោរព បានធ្វើសេចក្តីសន្និដ្ឋានថា ចំណីអាហារប្រើបច្ចេកវិទ្យាជីវសាស្ត្រ គឺមានសុវត្ថិភាព ដែលរួមមាន៖

- បណ្ឌិតសភាជាតិផ្នែកវិទ្យាសាស្ត្រ (NAS)
- ក្រុមប្រឹក្សាអាមេរិកផ្នែកវិទ្យាសាស្ត្រ និងសុខភាព (ACSH)
- បណ្ឌិតសភាផ្នែកអាហារូបត្ថម្ភ និងចំណីអាហារ (AND)
- អង្គការសុខភាពពិភពលោក (WHO)

*"មិនមានយុត្តិកម្មផ្នែកវិទ្យាសាស្ត្រសម្រាប់ការបិទស្លាកពិសេសនៅលើចំណីអាហារផលិតតាមការវិស្វកម្មពន្ធុឡើយ"* ។ —សមាគមវេជ្ជសាស្ត្រអាមេរិក ខែមិថុនា ឆ្នាំ 2012 ។

សំណើប្រជាមតិលេខ 37 ៖ ពោរពេញទៅដោយនិយត្តិកម្មតាមអំពើចិត្ត និងការលើកលែងដើម្បីផលប្រយោជន៍ពិសេស

*"បទបញ្ញា និងការលើកលែងតាមទំនើងចិត្តនៅក្នុងសំណើប្រជាមតិ 37 នេះនឹងផ្តល់នូវផលប្រយោជន៍ពិសេសជាក់លាក់មួយចំនួន ក៏ប៉ុន្តែមិនធ្លាក់ដល់ដៃអ្នកប្រើប្រាស់នោះទេ"* ។ — Dr. Christine Bruhn ក្រសួងវិទ្យាសាស្ត្រចំណីអាហារ និងបច្ចេកវិទ្យា នៃសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា UC Davis

សំណើប្រជាមតិ 37 គឺពោរពេញទៅដោយការលើកលែងដែលមិនសមហេតុផល និងមានការលើកទឹកចិត្តផ្នែកនយោបាយ។ វាតម្រូវឲ្យបិទស្លាកពិសេសនៅលើទឹកដោះគោ ផ្សំជាមួយសណ្តែកសៀង ក៏ប៉ុន្តែលើកលែងចំពោះទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះគោ។ ទឹកផ្លែឈើ គឺតម្រូវឲ្យមានស្លាក ប៉ុន្តែលើកលែងចំពោះគ្រឿងស្រវឹង។ ចំណីសត្វដែលមានផ្ទុកជាតិសាច់ តម្រូវឲ្យមានស្លាក ក៏ប៉ុន្តែលើកលែងចំពោះសាច់ផ្សេងៗសម្រាប់មនុស្សទទួលទាន។

ចំណីអាហារនាំចូលពីប្រទេសចិន និងប្រទេសមួយចំនួនផ្សេងទៀត ត្រូវបានលើកលែង ប្រសិនបើអ្នកលក់ទាំងឡាយអះអាងជាសាមញ្ញថា ផលិតផលរបស់ពួកគេ "មិនពាក់ព័ន្ធនឹងវិស្វកម្មពន្ធុ"។ ក្រុមហ៊ុនបរទេសនានាដែលមិនស្មោះត្រង់ អាចទាញយកផលប្រយោជន៍ពីប្រព័ន្ធនេះ។

សំណើប្រជាមតិលេខ 37 អនុញ្ញាតឲ្យមានបណ្តឹងទារយកប្រាក់សំណើនេះត្រូវបានសរសេរដោយមេធាវីជំនុំជម្រះម្នាក់ដើម្បីផ្តល់ផលប្រយោជន៍ដល់មេធាវីជំនុំជម្រះទាំងឡាយ។ វាបង្កើតនូវប្រភេទថ្មីមួយនៃ "រឿងក្តីជ្រើសរើសពិសេស" ដែលអនុញ្ញាតឲ្យមេធាវីធ្វើការប្តឹងគ្រួសារកសិករ និងអ្នកលក់គ្រឿងទេសដោយមិនមានភស្តុតាងណាមួយអំពីភយន្តរាយ។

*ពលរដ្ឋកាលីហ្វ័រញ៉ាដែលប្រឆាំងនឹងការរំលោភបំពានរឿងក្តីលើកឡើងថា "សំណើប្រជាមិត 37 អនុញ្ញាតឲ្យមេធាវីជំនុំជម្រះទាំងឡាយប្រើប្រាស់រឿងក្តីទាមទារយកប្រាក់ដើម្បីជំរិតយកប្រាក់ពីគ្រួសារកសិករ និងអ្នកលក់គ្រឿងទេស - ដែលធ្វើឲ្យតុលាការក្នុងរដ្ឋកាលីហ្វ័រញ៉ា អាជីវកម្ម និងអ្នកបង់ពន្ធចំណាយប្រាក់រាប់លានដុល្លារ"*។

សំណើប្រជាមតិ 37 ៖ ការិយាធិបតេយ្យកាន់តែច្រើននឹងការចំណាយ សម្រាប់អ្នកបង់ពន្ធកាន់តែច្រើន

សំណើប្រជាមតិ 37 តម្រូវឲ្យក្រារិយាលេខានុការរដ្ឋគ្រប់គ្រងល័ក្ខខ័ណ្ឌតម្រូវដ៏ស្មុគស្មាញរបស់ខ្លួនតាមរយៈធ្វើការពិនិត្យតាមដានមើលស្លាកចំណីអាហារចំនួនរាប់សិបពាន់។ វាមិនបានកំណត់ពីចំនួនទឹកប្រាក់ប៉ុន្មានលានដែលត្រូវចំណាយទៅលើការិយាធិបតេយ្យ ច្បាប់ទម្លាប់ការិយាធិបតេយ្យស្មុគស្មាញ និងរឿងក្តីនានានោះទេ។ វាគឺជាសែកចំហ.........ដែលបង់ប្រាក់ដោយអ្នកបង់ពន្ធ។

សំណើប្រជាមតិ 37 មានន័យថា ថ្លៃចំណីអាហារកាន់តែខ្ពស់

សំណើប្រជាមតិ 37 បង្ខំកសិករ និងក្រុមហ៊ុនផលិតចំណីអាហារឲ្យអនុវត្តប្រតិបត្តិការថ្មីដែលមានតំលៃខ្ពស់ ឬ ឲ្យប្តូរទៅប្រើគ្រឿងផ្សំដែលមានតម្លៃខ្ពស់ មិនធ្វើវិស្វកម្មពន្ធុ ឬសរីរាង្គសម្រាប់លក់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

ការសិក្សាផ្នែកសេដ្ឋកិច្ចបង្ហាញថា ប្រការនេះនឹងបង្កើនការចំណាយទៅលើចំណីអាហារសម្រាប់គ្រួសារជាមធ្យមរាប់រយដុល្លារជារៀងរាល់ឆ្នាំ-ដែលជាពន្ធចំណីអាហារមើលមិនឃើញដែលនឹងធ្វើឲ្យប៉ះពាល់ យ៉ាងខ្លាំងដល់មនុស្សចាស់ និងគ្រួសារដែលមានប្រាក់ចំណូលទាបដែលអាចមានលទ្ធភាពតិចតួចបំផុតក្នុងការទិញវា។

*"សំណើប្រជាមតិ 37 នឹងធ្វើឲ្យប៉ះពាល់ដល់គ្រួសារកសិករ និងអ្នកប្រើប្រាស់យ៉ាងអយុត្តិធម៌។ ដូច្នេះត្រូវតែបញ្ឈប់វា។"* —សហព័ន្ធការិយាល័យកសិដ្ឋានរដ្ឋកាលីហ្វ័រញ៉ាដែលតំណាងឲ្យកសិករចំនួន 80,000 នាក់។

ចូលរួមជាមួយអ្នកវិទ្យាសាស្ត្រ អ្នកជំនាញវេជ្ជសាស្ត្រ គ្រួសារកសិករ អ្នកតស៊ូមតិរបស់អ្នកបង់ពន្ធ អាជីវកម្មខ្នាតតូច។

បោះឆ្នោត ទេ លើសំណើប្រជាមតិ លេខ 37។

បញ្ឈប់ការកលល្បិច បិទផ្លាកចំណីអាហារ ឆបោក អស់ថ្លៃចំណាយដ៏ច្រើននេះ។

*www.NoProp37.com*

**DR. BOB GOLDBERG**, សមាជិក
បណ្ឌិតសភាជាតិនៃវិទ្យាសាស្ត្រ
**JAMIE JOHANSSON**
គ្រួសារកសិករកាលីហ្វ័រញ៉ា
**BETTY JO TOCCOLI**, ប្រធាន
សមាគមអាជីវកម្មខ្នាតតូចកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 37 ★

37

*សំណើប្រជាមតិ 37៖ និយាយ "យល់ព្រម" ដើម្បីដឹងពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក។*

*សំណើប្រជាមតិ 37 មានន័យយ៉ាងសាមញ្ញថា អ្នកមានសិទ្ធិដឹងពីអ្វីនៅក្នុងចំណីអាហាររបស់អ្នក។ មធ្យោបាយសម្រាប់ធ្វើការងារនោះ គឺត្រូវធ្វើឲ្យប្រាកដថាស្លាកបិទលើចំណីអាហារ គឺពិតជាត្រឹមត្រូវ។*

*សំណើប្រជាមតិ 37 ដាក់អ្នកឲ្យទទួលខុសត្រូវ។* គ្មានការិយាធិបតេយ្យរដ្ឋាភិបាល អ្នកនយោបាយ ឬ ក្រុមហ៊ុនកសិគីមីណាមួយនឹងអាចមានលទ្ធភាពបិទបាំងបានឡើយប្រសិនបើចំណីអាហាររបស់អ្នកត្រូវបានផលិតឡើងតាមការកែច្នៃពន្ធុនោះឬក៏អត់។ ការអនុវត្ត គឺជាកិច្ចការតែមួយគត់ ប្រសិនបើក្រុមហ៊ុនទាំងឡាយនោះរំលោភច្បាប់! អ្វីគ្រប់យ៉ាងដែលពួកគេត្រូវធ្វើ គឺត្រូវប្រាប់អ្នកអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក ដូចដែលពួកគេបានធ្វើរួចមកហើយនៅក្នុងប្រទេសផ្សេងៗជាង 40 ទូទាំងទ្វីបអឺរ៉ុប ប្រទេសអូស្ត្រាលី ជប៉ុន និងសូម្បីប្រទេសចិន និងរុស្ស៊ី។

*សំណើប្រជាមតិ 37 មិនហាមឃាត់ចំណីអាហារវិស្វកម្មពន្ធុនោះទេ។* ក្រុមហ៊ុនអាជីវកម្មកសិកម្ម និងកសិគីមីធំៗ និងអ្នកបញ្ចុះបញ្ចូលរបស់ពួកគេចង់បន្លាចអ្នក។ ក្រោមសំណើប្រជាមតិ 37 អ្នកអាចបន្តទិញចំណីអាហារក្នុងពេលបច្ចុប្បន្នរបស់អ្នក ឬ អ្នកអាចជ្រើសរើសអាហារផ្សេងៗដែលមិនកែច្នៃពន្ធុ។ វាគឺជាជម្រើសរបស់អ្នក។

*សំណើប្រជាមតិ 37 មិនបង្កើនតម្លៃចំណីអាហារ ឬពន្ធដារនោះទេ។* ព្រោះតែក្រុមហ៊ុនចំណីអាហារបោះពុម្ពស្លាកឡើងវិញជាទៀងទាត់ និងមានជំហានសមស្របនៅក្នុងអំឡុងពេលមួយ សំណើប្រជាមតិ 37 នឹងមិនបង្កើនតម្លៃឡើយ។

*សំណើប្រជាមតិ 37 នឹងជួយការពារសុខភាពគ្រួសាររបស់អ្នក។* រដ្ឋបាលគ្រប់គ្រងចំណីអាហារ និងឱសថ (FDA) និយាយថា "ការផ្តល់ព័ត៌មានច្រើនដល់អ្នកប្រើប្រាស់អំពីអាហារដែលផលិតដោយកែប្រែជីវសាស្ត្រនឹងមានអត្ថប្រយោជន៍"។ ប្រសិនមិនមានការបិទស្លាកចំណីអាហារច្បាស់លាស់ទេ អ្នកនឹងប្រថុយប្រថានទទួលទានអាហារដែលអ្នកប្រតិកម្មជាមួយវា។ ហេតុអ្វីក្រុមហ៊ុនចំណីអាហារធំៗមិនចង់ឲ្យអ្នកដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក? ដោយមានវិទ្យាសាស្ត្រដ៏ចម្រូងចម្រាស់ និងមិនប្រាកដប្រជាអំពីផលប៉ះពាល់ផ្នែកសុខភាពនៃចំណីអាហារកែច្នៃពន្ធុ ការបិទស្លាក គឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការពារសុខភាពគ្រួសាររបស់អ្នក។

យើងមានសិទ្ធិដឹងពីអ្វីនៅក្នុងចំណីអាហាររបស់យើង។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 37។

*www.Carighttoknow.org*

**JAMIE COURT**, ប្រធាន
ក្រុមឃ្លាំមើលអ្នកប្រើប្រាស់
**JIM COCHRAN**, អគ្គនាយក
កសិដ្ឋាន បែរី Swanton
**DR. MARCIA ISHII-EITEMAN**, អ្នកវិទ្យាសាស្ត្រ ជាន់ខ្ពស់
បណ្តាញសកម្មភាព ថ្នាំសំឡាប់សត្វចង្រៃ